**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
******

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

នៅរសៀលថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ២០១៩ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានអនុញ្ញាតជូន**លោកសាស្ត្រាចារ្យ** Jean-Paul de GAUDEMAR សាកលវិទ្យាធិការទីភ្នាក់ងារឧត្តមសិក្សានៃបណ្តាប្រទេសប្រើប្រាស់ភាសាបារាំង (AUF) ចូលជួបសំដែងការគួរសម នៅទីស្តីការក្រសួង។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍**លោកសាស្ត្រាចារ្យ**ដែលបានមកធ្វើទស្សនកិច្ចនៅកម្ពុជាលើកទី១ និងមានរយៈពេលយូរ (៣ថ្ងៃ) ដែលជាការយកចិត្តទុកដាក់របស់**លោកសាស្ត្រាចារ្យ** ចំពោះប្រទេសកម្ពុជា ក្នុងការចែករំលែកបទពិសោធន៍ ជំនាញ និងទស្សនវិស័យក្នុងការលើកកម្ពស់គុណភាពអប់រំថ្នាក់ឧត្តមសិក្សា និងហ្វ្រង់កូហ្វូនីនៅកម្ពុជា។

ជាកិច្ចឆ្លើយតប **លោកសាស្ត្រាចារ្យ** Jean-Paul de GAUDEMAR បានលើកឡើងថា លោកមានសេចក្តីរីករាយណាស់ដែលបានមកទស្សនកិច្ចនៅកម្ពុជានៅពេលនេះ ក្នុងនាមជាសាកលវិទ្យាធិការនៃទីភ្នាក់ងារឧត្តមសិក្សា AUF។ ចំពោះ**លោកសាស្ត្រាចារ្យ** កម្ពុជាជាប្រទេសមួយដែលហ្វ្រង់កូហ្វូនីចាក់ឫសនូវអត្ថន័យនិងតំលៃប្រកបដោយភាពត្រឹមត្រូវតាមច្បាប់ ដោយសារ **ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** ដែលជាស្ថាបនិកដ៏សំខាន់មួយរូបរបស់អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី (OIF)។

AUF ប្រមូលផ្តុំគ្រឹះស្ថានឧត្តមសិក្សានិងស្រាវជ្រាវនៃបណ្តាប្រទេសប្រើប្រាស់ភាសាបារាំង ចំនួន **៩០៩** មកពី **១១៣** ប្រទេស តែងតែជួយដល់សមាជិករបស់ខ្លួនដោះស្រាយបញ្ហាប្រឈមដូចជា បញ្ហាគុណភាពនៃការបណ្តុះបណ្តាល ការស្រាវជ្រាវ អភិបាលកិច្ចសកលវិទ្យាល័យ និងបញ្ហារកការងារធ្វើបន្ទាប់ពីបញ្ចប់ការសិក្សា ។ AUF ត្រៀមសហការជានិច្ចជាមួយកម្ពុជា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ថា កម្ពុជាមានឆន្ទៈនយោបាយពិតប្រាកដក្នុងការលើកតម្កើងហ្វ្រង់កូហ្វូនី ដែលបន្តពីស្នាព្រះហស្ថរបស់ **ព្រះករុណា ព្រះបរមរតនកោដ្ឋ។** នៅក្នុងក្របខណ្ឌនេះ កម្ពុជាតែងតែចូលរួមយ៉ាងសកម្មនៅក្នុងស្ថាប័នសំខាន់ៗរបស់អង្គការOIF រួមមាន ក្រុមប្រឹក្សាអចិន្ត្រៃយ៍ហ្វ្រង់កូហ្វូនីសន្និសីទថ្នាក់រដ្ឋមន្ត្រីការបរទេសហ្វ្រង់កូហ្វូនី និងកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី និងមានកិច្ចសហការយ៉ាងល្អជាមួយ ប្រតិបត្តិកររបស់ហ្វ្រង់កូហ្វូនី រួមមាន ភ្នាក់ងារឧត្តមសិក្សានៃបណ្តាប្រទេសប្រើប្រាស់ភាសាបារាំង សមាគមអន្តរជាតិនៃអភិបាលក្រុងប្រើប្រាស់ភាសាបារាំង និងសភានៃបណ្តាប្រទេសនិយាយភាសាប្រើប្រាស់។

សមាជិករាជរដ្ឋាភិបាលភាគច្រើនអាចនិយាយភាសាបារាំងបានយ៉ាងស្ទាត់ជំនាញ។

នៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ មាន**នាយកដ្ឋានហ្វ្រង់កូហ្វូនី** ដែលមានតួនាទីសម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធជាមួយអង្គការអន្តរជាតិ និងរ៉ាប់រងលើដំណើរការរបស់កិច្ចប្រជុំក្រុមប្រឹក្សាលើកតម្កើងហ្វ្រង់កូហ្វូនីនៅកម្ពុជា (CPFC)។

ចាប់តាំងពីឆ្នាំ២០០៦មក កម្ពុជាបានចូលរួមចំណែកយ៉ាងសកម្មនៅក្នុងបេសកកម្មរក្សាសន្តិភាពរបស់អ.ស.ប. ដោយបានបញ្ជូនកងកម្លាំងជាង **៦.០០០ នាក់** ទៅបណ្តាប្រទេសអាហ្វ្រិកមួយចំនួន ជាពិសេសប្រទេសសមាជិកហ្វ្រង់កូហ្វូនី រួមមានប្រទេស ម៉ាលី លីបង់ និងសាធារណរដ្ឋអាហ្វ្រិកកណ្តាលជាដើម។

នៅក្នុងខែធ្នូ ឆ្នាំ២០១៩ នេះ កម្ពុជានឹងធ្វើជាម្ចាស់ផ្ទះនៃមហាសន្និបាតលើកទី ៣៩ របស់សមាគមអន្តរជាតិអភិបាលក្រុងដែលនិយាយភាសាបារាំង។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មានសេចក្តីរីករាយ ដោយគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាចំនួន១០ បានចូលជាសមាជិកទីភ្នាក់ងារឧត្តមសិក្សា AUF រួចហើយ និងបានលើកឡើងថា **វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ** នឹងចូលជាសមាជិក AUF នៅពេលខាងមុខ។

**លោកសាស្ត្រាចារ្យ** បានអះអាងតបវិញថា លោករីករាយនឹងជួយសម្រួលឲ្យ**វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ** របស់កម្ពុជា បានចូលជាសមាជិករបស់ទីភ្នាក់ងារឧត្តមសិក្សា AUF ផងដែរ។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល ៕

ថ្ងៃសុក្រ ៧ កើត ខែពិសាខ ឆ្នាំកុរ សំរឹទ្ធិស័ក ព.ស ២៥៦២
ភ្នំពេញ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០១៩